Victorian Equal Opportunity & Human Rights Commission

Khmer | ភាសាខ្មែរ

# ការរើសអើងពូជសាសន៍នៅកន្លែងធ្វើការ៖ តើសិទ្ធិរបស់ខ្ញុំមានអ្វីខ្លះ?

ក្នុងនាមជានិយោជិក អ្នកត្រូវបានការពារពីការរើសអើងពូជសាសន៍នៅក្រោម*ច្បាប់ស្តីពីឱកាសស្មើគ្នា ឆ្នាំ 2010* (រដ្ឋវិចថូរៀ)។

នៅក្រោមច្បាប់ស្តីពីឱកាសស្មើគ្នា វាខុសច្បាប់ចំពោះនិយោជិតដែលត្រូវបានគេរើសអើងដោយផ្អែកលើពូជសាសន៍របស់ពួកគេ។ នេះរាប់បញ្ចូលទាំងពណ៌សម្បុរស្បែក ដើមកំណើត ឬជាតិពង្ស សញ្ជាតិ ប្រវត្តិជនជាតិភាគតិច ឬបុគ្គលិកលក្ខណៈណាមួយដែលទាក់ទងនឹងពូជសាសន៍ជាក់លាក់មួយ (លុះត្រាតែមានករណីលើកលែង)។

នៅក្រោម*ច្បាប់ស្តីពីការអត់ឱនខាងពូជសាសន៍ និងសាសនា ឆ្នាំ 2001* (រដ្ឋវិចថូរៀ) ការនិយាយមួលបង្កាច់ – ការញុះញង់ជាសាធារណៈឱ្យមានការស្អប់ខ្ពើម ឬការចំអកជាសាធារណៈដោយផ្អែកលើសាសនា និង/ឬពូជសាសន៍ – ក៏ខុសច្បាប់ផងដែរ។

## តើនិយោជិតត្រូវបានការពារពីការរើសអើងពូជសាសន៍នៅកន្លែងណាខ្លះ?

ច្បាប់ស្តីពីឱកាសស្មើគ្នាការពារមនុស្សពីការរើសអើងនៅក្នុងផ្នែកសំខាន់ៗនៃជីវិតសាធារណៈ រួមទាំងការងារផងដែរ។ ការរើសអើងពូជសាសន៍អាចកើតឡើងនៅក្នុងឧស្សាហកម្ម ឬអង្គការណាមួយ នៅចំណុចណាមួយក្នុងវដ្តការងារ។

និយោជិត (រួមទាំងបុគ្គលិកដែលមានបៀវត្សរ៍ អ្នកហាត់ការដែលមានបៀវត្សរ៍ និងអ្នកដាក់ពាក្យសុំការងារ) និងអ្នកម៉ៅការត្រូវបានការពារ៖

- នៅកន្លែងធ្វើការ
- នៅកន្លែងរួម (ចំណតឡាន ជណ្តើរយន្ត កន្លែងទទួលភ្ញៀវ និងបន្ទប់ទឹក)
- ក្នុងអំឡុងពេលព្រឹត្តិការណ៍ កិច្ចប្រជុំ និងទីកន្លែងទាក់ទងនឹងការងារ (ឧទាហរណ៍ ពិធីជប់លៀង ឬការធ្វើដំណើរការងារ)
- នៅកន្លែងតាមអនឡាញ។

## តើការរើសអើងពូជសាសន៍ ការនិយាយមួលបង្កាច់ និងការធ្វើឱ្យនរណាម្នាក់រងគ្រោះ មើលមានលក្ខណៈទៅដូចអ្វីដែរនៅកន្លែងធ្វើការ?

ច្បាប់ស្តីពីឱកាសស្មើគ្នាហាមឃាត់ការរើសអើងនៅកន្លែងធ្វើការ។ នេះរួមបញ្ចូលទាំងការរើសអើងពូជសាសន៍ដែលប្រព្រឹត្តដោយនិយោជក និងនិយោជិតផ្សេងទៀត។ ឧទាហរណ៍មួយចំនួនអាចរួមមានជាតិសាសន៍និយមរវាងមនុស្ស (ទាំងមានលក្ខណៈបើកចំហដែលឥតលាក់លៀម និងមានលក្ខណៈប្រើល្បិចកលយ៉ាងប៉ិនប្រសប់) ការរំលោភបំពានតិចតួច ការលម្អៀងផ្នែកស្ថាប័ន និងអវិភាពចំពោះតម្រូវការផ្នែកវប្បធម៌។

- **ការរើសអើងពូជសាសន៍** អាចមានទាំងដោយផ្ទាល់ និងដោយប្រយោល។

  ការរើសអើងពូជសាសន៍ដោយផ្ទាល់ គឺនៅពេលដែលនរណាម្នាក់ប្រព្រឹត្តចំពោះមនុស្សម្នាក់ទៀតដោយអយុត្តិធម៌ ដោយសារតែពូជសាសន៍របស់ពួកគេ។

  > *ឧទាហរណ៍៖ និយោជកបដិសេធមិនទទួលយក ឬដំណើរការពាក្យសុំរបស់អ្នកដាក់ពាក្យសុំជាប្រជាជាតិដំបូង ដោយសារតែការសន្មតអវិជ្ជមាន និងមិនត្រឹមត្រូវអំពីជំនាញ ឬសីលធម៌ការងាររបស់ពួកគេ។*

  ការរើសអើងពូជសាសន៍ដោយប្រយោល។ គឺនៅពេលដែលមានលក្ខខណ្ឌតម្រូវមិនសមហេតុផល គោលនយោបាយ ឬការអនុវត្តនៅកន្លែងធ្វើការ ដែលមានគុណវិបត្តិ ឬប៉ះពាល់ដល់និយោជិតដោយអយុត្តិធម៌ ដោយសារតែពូជសាសន៍របស់ពួកគេ។

  > *ឧទាហរណ៍៖ ក្រុមហ៊ុនមួយកំណត់ និងដាក់ឱ្យអនុវត្តនូវកូដសម្លៀកបំពាក់សម្រាប់និយោជិតទាំងអស់ ដែលហាមនិយោជិតនានាមិនឱ្យពាក់មួកសុវត្ថិភាពនៅកន្លែងធ្វើការ ដែលនាំឱ្យមានគុណវិបត្តិដល់បុគ្គលិកដែលស្លៀកសម្លៀកបំពាក់ដែលមានសារៈសំខាន់ខាងសាសនា ឬវប្បធម៌នៅលើក្បាលរបស់ពួកគេ។*

- **ការនិយាយមួលបង្កាច់** គឺជាអាកប្បកិរិយាសាធារណៈដែលលើកទឹកចិត្តអ្នកដទៃឱ្យស្អប់ ឬចំអកដល់បុគ្គលម្នាក់ ឬក្រុមមនុស្សដោយផ្អែកលើពូជសាសន៍ ឬសាសនារបស់ពួកគេ។ ដើម្បីស្វែងយល់ពីភាពខុសគ្នារវាងការនិយាយមួលបង្កាច់ និងការរើសអើងពូជសាសន៍ សូមមើល 'ជំពូកទី 3៖ ការយល់ដឹងអំពីច្បាប់ស្តីពីជាតិសាសន៍និយមនៅកន្លែងធ្វើការ' នៅក្នុង*គោលការណ៍ណែនាំ៖ ការរើសអើងពូជសាសន៍នៅកន្លែងធ្វើការ* របស់យើង។

> *ឧទាហរណ៍៖ និយោជិតម្នាក់ចោទប្រកាន់សហសេវិកម្នាក់ថាជា 'ភ្នាក់ងារបរទេស' ដោយសារតែពូជសាសន៍របស់ពួកគេ និង 'ទទួលបានអាថ៌កំបាំងឧស្សាហកម្មដើម្បីផ្តល់ឱ្យរដ្ឋាភិបាលរបស់ពួកគេ' និងលើកទឹកចិត្តឱ្យមិត្តរួមការងារស្អប់មនុស្សទាំងអស់ដែលមកពីប្រវត្តិពូជសាសន៍ដូចគ្នា។*

- **ការធ្វើឱ្យនរណាម្នាក់រងគ្រោះ** គឺនៅពេលនិយោជិតម្នាក់ត្រូវបានគេប្រព្រឹត្តមកលើយ៉ាងធ្ងន់ធ្ងរ ដោយសារតែពួកគេបានលើកឡើងពីបញ្ហា ឬធ្វើការតវ៉ាអំពីការរើសអើងពូជសាសន៍ ឬជាតិសាសន៍និយម ឬការប្រព្រឹត្តខុសច្បាប់ផ្សេងទៀតដែលបានចោទប្រកាន់។

> *ឧទាហរណ៍៖ និយោជិតម្នាក់ដែលបានរាយការណ៍ពីអ្នកគ្រប់គ្រងរបស់ពួកគេចំពោះការប្រើពាក្យប្រមាថពូជសាសន៍នៅក្នុងការសន្ទនាបន្ទាប់មកត្រូវបានបណ្តេញចេញដោយអយុត្តិធម៌ ពីព្រោះពួកគេបានព្យាយាមរាយការណ៍ពីឧប្បត្តិហេតុនៃការរើសអើងពូជសាសន៍។*

## តើខ្ញុំអាចធ្វើអ្វីបាន ប្រសិនបើខ្ញុំបានជួបប្រទះការរើសអើងពូជសាសន៍នៅកន្លែងធ្វើការ?

ប្រសិនបើអ្នកបានជួបប្រទះការរើសអើងពូជសាសន៍ ឬការនិយាយមួលបង្កាច់នៅកន្លែងធ្វើការ អ្នកអាចទាក់ទងគណៈកម្មការទទួលបន្ទុកលើឱកាសស្មើគ្នា និងសិទ្ធិមនុស្សនៃរដ្ឋវិចថូរៀ ដើម្បីទទួលបានព័ត៌មាន ឬដាក់ពាក្យបណ្តឹង។

គណៈកម្មការនេះក៏មានកម្មវិធីកុំព្យូទ័រនិយាយជាមនុស្សរាយការណ៍ពីជាតិសាសន៍និយមមានអន្តរកម្មសម្ងាត់ផងដែរ ដែលអាចជួយអ្នកឱ្យយល់ដឹងពីសិទ្ធិរបស់អ្នក និងរាយការណ៍ពីការរើសអើងពូជសាសន៍ និងការនិយាយមួលបង្កាច់។

អ្នកអាចហៅទូរសព្ទទៅបណ្តាញទូរសព្ទសាកសួរដោយឥតគិតថ្លៃរបស់គណៈកម្មការតាមលេខ 1300 292 153 ឬចូលមើលគេហទំព័ររបស់យើង humanrights.vic.gov.au។

| **អង្គការផ្សេងទៀតដែលអ្នកអាចទាក់ទងសម្រាប់ព័ត៌មានបន្ថែម** | |
|---|---|
| **Victoria Legal Aid (ជំនួយផ្លូវច្បាប់រដ្ឋវិចថូរៀ)** | សេវាផ្លូវច្បាប់ដោយឥតគិតថ្លៃ ដើម្បីគាំទ្រដល់មនុស្សដែលមានបញ្ហាផ្លូវច្បាប់ រួមមានជាតិសាសន៍និយម ការរើសអើង ការយាយី និងការសម្លុតធ្វើបាប។<br>ទូរសព្ទ 1300 792 387<br>តាមអនឡាញ legalaid.vic.gov.au |
| **Victorian Aboriginal Legal Service (សេវាផ្លូវច្បាប់រដ្ឋវិចថូរៀសម្រាប់ជនជាតិដើម Aboriginal)** | ព័ត៌មានផ្លូវច្បាប់ដោយឥតគិតថ្លៃសម្រាប់ ប្រជាជនជាជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait នៅរដ្ឋវិចថូរៀ អំពីបញ្ហាផ្លូវច្បាប់ជាច្រើន រួមទាំងការរើសអើងផងដែរ។<br>ទូរសព្ទ 1800 064 865<br>តាមអនឡាញ vals.org.au |
| **JobWatch** | ព័ត៌មានផ្លូវច្បាប់ និងការគាំទ្រដោយឥតគិតថ្លៃលើបញ្ហាទាក់ទងនឹងសិទ្ធិការងារ រួមទាំងការរើសអើង។<br>ទូរសព្ទ (03) 9662 1933 (នៅតាមតំបន់ជុំវិញក្រុង), 1800 331 617 (នៅតាមតំបន់រដ្ឋវិចថូរៀ) តាមអនឡាញ jobwatch.org.au |
| **គណៈកម្មការសមភាពការងារ (Fair Work Commission)** | កម្មវិធីជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ដើម្បីផ្តល់ជូនដំបូន្មានស្តីពីបញ្ហាផ្លូវច្បាប់នានា រួមទាំងការសម្លុតធ្វើបាបនៅកន្លែងធ្វើការ។<br>ទូរសព្ទ 1300 799 675<br>តាមអនឡាញ www.fwc.gov.au |

សម្រាប់ព័ត៌មានបន្ថែម សូមទាញយក*គោលការណ៍ណែនាំ៖ ការរើសអើងពូជសាសន៍នៅកន្លែងធ្វើការ* របស់គណៈកម្មការ ដែលមាននៅតាមគេហទំព័រ humanrights.vic.gov.au/resources ឬតាមរយៈកូដ QR។

*ព័ត៌មាននេះមានគោលបំណងជាការណែនាំប៉ុណ្ណោះ។ វាមិនមែនជាការជំនួសសម្រាប់ដំបូន្មានផ្នែកច្បាប់ទេ។*